# បុព្វកថា

ក្រសួងអប់រំ យុវជន និងកីឡា មានសេចក្តីរីករាយក្រៃលែង និងមោទកភាព ដែលបានបោះពុម្ពផ្សាយលើកដំបូង **ឆ្នាំទី១ លេខ១ ក្នុងទស្សនាវដ្តីស្រាវជ្រាវកម្ពុជាសម្រាប់ការអប់រំ និងស្ទែម** (ទ.ក.អ.ស.) និងឈ្មោះជាភាសាអង់គ្លេស Cambodian Journal of Education and STEM (CJES)។ ទស្សនាវដ្តីស្រាវជ្រាវ បោះពុម្ពជាភាសាខ្មែរនេះ ជាគំនិតផ្តួចផ្តើមមួយ ក្នុងចំណោមគំនិតផ្តួចផ្តើមថ្មីៗជាច្រើន ដែលក្រសួងអប់រំ យុវជន និងកីឡា បាននិងកំពុងអនុវត្ត ដើម្បីជំរុញ និងអភិវឌ្ឍការស្រាវជ្រាវនៅឧត្តមសិក្សាក៏ដូចជាក្នុងប្រទេសកម្ពុជាទាំងមូល។ ទស្សនាវដ្តីស្រាវជ្រាវនេះ ជាជំហានមួយដ៏សំខាន់ ក្នុងការផលិតឯកសារស្រាវជ្រាវក្នុងស្រុក ដើម្បីបង្កភាពងាយស្រួលដល់ការសិក្សាស្រាវជ្រាវរបស់លោកគ្រូ អ្នកគ្រូ និស្សិត និងអ្នកស្រាវជ្រាវកម្ពុជា។

ក្នុងអំឡុងពេលជាងមួយទស្សវត្សរ៍កន្លងមកនេះ ក្រសួងបានអនុវត្តគម្រោងស្រាវជ្រាវជាច្រើន ជាមួយគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងឯកជន ដើម្បីកសាងមូលដ្ឋានគ្រឹះសម្រាប់អភិវឌ្ឍការស្រាវជ្រាវនៅឧត្តមសិក្សា។ ផ្តើមចេញពីការកសាងមូលដ្ឋានគ្រឹះនេះ ក្រសួងបាននិងកំពុងអនុវត្តគម្រោងស្រាវជ្រាវធំៗបន្ថែមទៀត ដោយផ្តោតលើការផ្សារភ្ជាប់ការស្រាវជ្រាវផ្នែកស្ទែម និងកសិកម្មទៅនឹងការធ្វើអាជីវកម្ម និងអភិវឌ្ឍវិស័យឧស្សាហកម្ម ក្នុងនោះមន្ទីរពិសោធន៍ កសិដ្ឋាន និងហេដ្ឋារចនាសម្ព័ន្ធស្រាវជ្រាវជាច្រើន ត្រូវបានកសាង និងធ្វើទំនើបកម្ម ដោយបំពាក់នូវសម្ភារៈ និងឧបករណ៍ទំនើបៗ។ ក្រសួងក៏បានកំណត់ការបោះពុម្ពអត្ថបទស្រាវជ្រាវក្នុងទស្សនាវដ្តីស្រាវជ្រាវជាតិ និងអន្តរជាតិ ជាសូចនាករអាទិភាព ក្នុងគម្រោងវិនិយោគនាពេលបច្ចុប្បន្នផងដែរ។ ការរៀបចំឱ្យមានទស្សនាវដ្តីស្រាវជ្រាវ សម្រាប់បោះពុម្ពផ្សាយអត្ថបទស្រាវជ្រាវជាភាសាខ្មែរនេះ នឹងរួមចំណែកក្នុងការកសាងប្រព័ន្ធអេកូឡូស៊ីសម្រាប់ការស្រាវជ្រាវនៅកម្ពុជា ជាពិសេសគាំទ្រការអនុវត្តឱ្យសម្រេចបាននូវសូចនាករ នៃការបោះពុម្ពផ្សាយអត្ថបទស្រាវជ្រាវផងដែរ។

ជាមួយនឹងគំនិតផ្តួចផ្តើមនេះ ក្រសួងអប់រំ យុវជន និងកីឡា សូមគាំទ្រ និងលើកទឹកចិត្តដល់គ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងឯកជន ជាពិសេសអ្នកស្រាវជ្រាវទាំងអស់ ឱ្យបន្តចូលរួមយ៉ាងសកម្មក្នុងការបោះពុម្ពផ្សាយអត្ថបទស្រាវជ្រាវ ដែលមានលក្ខណៈវិទ្យាសាស្ត្រ ជាភាសាខ្មែរ ដើម្បីបង្កើនធនធានសិក្សាសម្រាប់បម្រើដល់ការរៀន ការបង្រៀន និងការស្រាវជ្រាវនៅកម្ពុជា។

ក្នុងនាមក្រសួងអប់រំ យុវជន និងកីឡា ខ្ញុំសូមកោតសរសើរ និងវាយតម្លៃខ្ពស់ ចំពោះថ្នាក់ដឹកនាំក្រសួង ថ្នាក់ដឹកនាំអគ្គនាយកដ្ឋានឧត្តមសិក្សា ថ្នាក់ដឹកនាំនាយកដ្ឋាន ថ្នាក់គ្រប់គ្រងការិយាល័យ និងមន្ត្រី នៃនាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ និងជាពិសេសក្រុមប្រឹក្សាពិគ្រោះយោបល់ និពន្ធនាយក និពន្ធនាយករង និងក្រុមបច្ចេកទេស នៃទស្សនាវដ្តីស្រាវជ្រាវកម្ពុជាសម្រាប់ការអប់រំ និងស្ទែម ដែលបានខិតខំប្រឹងប្រែង ប្រកបដោយការប្តេជ្ញាចិត្ត និងការយកចិត្តទុកដាក់ខ្ពស់ ក្នុងការរៀបចំបោះពុម្ពផ្សាយទស្សនាវដ្តីស្រាវជ្រាវដ៏មានសារៈសំខាន់នេះឡើង។

ជាទីបញ្ចប់ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា លោកគ្រូ អ្នកគ្រូ អ្នកស្រាវជ្រាវ និស្សិត និងអ្នកអានទាំងអស់ ទទួលបានចំណេះដឹងថ្មីៗ ពាក់ព័ន្ធនឹងវិស័យអប់រំ និងស្ទែម និងអាចប្រើប្រាស់ចំណេះដឹងទាំងនោះ ដើម្បីលើកកម្ពស់គុណភាពនៃការបង្រៀន និងការរៀន និងជំរុញការស្រាវជ្រាវបន្តទៀត។

ថ្ងៃ អង្គារ ១៥កើត ខែ ផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែមីនា ឆ្នាំ២០២៣

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**